# សុន្ទរកថា

## ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## និងជាប្រធាន គ.ជ.អ.ប

## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបសមិទ្ធផលការងារ

## ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២

ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១១

- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តមប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស
- ឯកឧត្តម លោកជំទាវ តំណាងគណបក្សនយោបាយ
- ឯកឧត្តមអភិបាល អភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ
- លោកប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់
- អស់លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលនានា
- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !

ថ្ងៃនេះខ្ញុំមានបិតិសោមនស្សរីករាយជាអនេក ចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល នៅក្នុងអង្គសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ នាឱកាសដ៏មហោឡារិកនេះ។

ដូចសព្វមួយដង រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ខ្ពស់ផ្តល់ការដឹកនាំដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រៀបចំសន្និបាតនេះឡើងសម្រាប់ផ្តល់

ឱកាសដល់អ្នកពាក់ព័ន្ធនានា រួមគ្នាពិនិត្យ វាយតម្លៃអំពីសមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយនៅក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ។

សន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ បានប្រារព្ធធ្វើឡើងក្នុងបរិយាកាសនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ បានដាក់ឱ្យអនុវត្តនៅថ្នាក់ក្រោមជាតិទាំងមូល ។

ដូច្នេះ សន្និបាតនេះ យើងមិនគ្រាន់តែលើកយកសមិទ្ធផល បញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារក្នុងក្របខ័ណ្ឌតែក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២មកធ្វើការពិភាក្សាប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈសន្និបាតនេះ អ្នកពាក់ព័ន្ធនានានឹងមានឱកាសដើម្បីធ្វើការពិភាក្សាវាយតម្លៃអំពីសមិទ្ធផល និងបញ្ហាប្រឈមនៃកំណែទម្រង់នៅថ្នាក់ក្រោមជាតិទាំងមូល ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

ក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្ដល់នូវភ័ស្តុតាងតាមរយៈការយល់ដឹងជាទូទៅ និងជំនឿយ៉ាងមុតមាំពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍នានាថា គោលនយោបាយនេះបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការចូលរួមកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ បានក្លាយទៅជាអង្គបោះឆ្នោតដ៏សំខាន់ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ។

ការបង្កើតឡើងនូវក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់នូវសមិទ្ធផលទាំងឡាយដែលក្រុមប្រឹក្សាឃុំ សង្កាត់ របស់យើងសម្រេចបានចាប់តាំងពីអាណត្តិទី១ រហូតមកដល់បច្ចុប្បន្ន។ សមិទ្ធផលនេះបានធ្វើឱ្យមានការផ្លាស់ប្តូរនូវខ្សែគណនេយ្យភាពក្នុងចំណោមថ្នាក់រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់នូវតម្លាភាព ប្រសិទ្ធភាព ភាពជឿទុកចិត្តបាន និងការឆ្លើយតបទៅនឹងតម្រូវការជាប្រចាំរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលក្រុមប្រឹក្សា និងរដ្ឋបាលរបស់ខ្លួនត្រូវទទួលស្គាល់ និងប្រឹងប្រែងឆ្លើយតប ។

ឆ្លៀតឱកាសដ៏មហោឡារិកនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះកិច្ចខិតខំប្រឹងប្រែង និងការគាំទ្រនានា ដែលឯកឧត្តម លោកជំទាវ លោកស្រី អស់លោក បាននឹងកំពុងបន្តជួយគាំទ្រយ៉ាងពេញទំហឹងក្នុងការអនុវត្តគោលនយោបាយ

កំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

ឆ្លងកាត់ការអនុវត្តគោលនយោបាយកំណែទម្រង់នេះនៅថ្នាក់ឃុំ សង្កាត់ រយៈពេលជិតមួយទសវត្សន៍កន្លងមក បានធ្វើឱ្យមានការយល់ដឹងយ៉ាងទូលំទូលាយជាងមុន ទាំងក្នុងស្ថាប័នជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍន៍នានា អំពីសារៈសំខាន់នៃកំណែទម្រង់នេះក្នុងដំណើរការកសាងសង្គមជាតិឡើងវិញ។ សមិទ្ធផលនៃកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ បានលើកទឹកចិត្តឱ្យយើងបោះជំហានចូលដល់ដំណាក់កាលកែទម្រង់កាន់តែស៊ីជម្រៅថែមទៀតនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ។ យើងទាំងអស់គ្នាពិតជាមានមោទនភាពចំពោះលទ្ធផលជាផ្លែផ្កាទាំងនេះ ដែលសុទ្ធសឹងបង្ហាញឱ្យឃើញច្បាស់ពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលទាំងមូល ដោយមានការចូលរួមពីស្ថាប័ន អង្គការនានា ដែលមានឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាតំណាងមានវត្តមាននៅទីនេះ។ សព្វថ្ងៃនេះ បរិបទនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំពុងត្រូវបានយកចិត្តទុកដាក់ពីសំណាក់ស្ថាប័ននានាទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន ដែលនេះជាចលករមួយក្នុងការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពដើម្បីអភិវឌ្ឍន៍នៅមូលដ្ឋាន ដែលជាការរួមចំណែកក្នុងការសម្រេចបានគោលនយោបាយរបស់ជាតិក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ ។

កម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្តល់នូវផែនទីបង្ហាញផ្លូវរយៈពេលវែងមួយអំពីទស្សនវិស័យ យុទ្ធសាស្ត្រ ជំហាន និងដំណាក់កាលនានា និងសម្រាប់ជាការតម្រង់ទិសក្នុងដំណើរការកំណែទម្រង់នេះ ដើម្បីបង្ការមិនឱ្យមានការខុសឆ្គងណាមួយខាងផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងដំណើរការកំណែទម្រង់ដ៏សាំញ៉ាំនេះ ។

ផ្អែកតាមកម្មវិធីជាតិរយៈពេល១០ឆ្នាំ យើងបានកសាងនូវផែនការអនុវត្តសម្រាប់រយៈពេល៣ឆ្នាំដំបូង ដោយផ្តោតការយកចិត្តទុកដាក់លើការរៀបចំស្ថាប័ន រចនាសម្ព័ន្ធ ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានកំណត់យកថ្នាក់ក្រុង ស្រុក ជាថ្នាក់រដ្ឋបាលមូលដ្ឋានមួយទៀត ដែលដើរតួនាទីជាគន្លឹះរួមជាមួយឃុំសង្កាត់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន និងជាថ្នាក់គាំទ្រខាងបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ផងដែរ។ ប្រការនេះបានបំបាត់ចោលនូវទស្សនៈមួយចំនួនកន្លងមកដែលបានលើកឡើងថា រាជរដ្ឋាភិបាលបានបំភ្លេចចោលថ្នាក់ក្រុង ស្រុកនៅក្នុងគោលនយោបាយកំណែទម្រង់របស់ខ្លួន។

## ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !

ផ្អែកតាមទស្សនវិស័យ និងវិសាលភាពនៃកំណែទម្រង់នេះ គឺមានការពាក់ព័ន្ធទាំងការកែទម្រង់ផ្នែកនយោបាយ និងផ្នែករដ្ឋបាល។ កំណែទម្រង់ផ្នែកនយោបាយមានការពាក់ព័ន្ធដល់តួនាទី មុខងារ និងការ